**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ប័ណ្ណព្រំដែនកម្ពុជា-ថៃ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការគ្រប់គ្រង និងការប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ថៃ នៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីគោលការណ៍ និងយន្តការនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ សម្រាប់ប្រើប្រាស់ក្នុងការចេញចូលឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ ស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ។

**មាត្រា ៤.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅៈ

- **ប័ណ្ណព្រំដែនកម្ពុជា-ថៃ** សំដៅដល់ឯកសារធ្វើដំណើរមានដែនកំណត់ដែលចេញឲ្យប្រើដោយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាសម្រាប់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ ប្រើប្រាស់ក្នុងការចេញចូលឆ្លងកាត់ព្រំដែនរយៈពេលខ្លី ស្របទៅតាមគោលការណ៍កំណត់។
- **ច្រកទ្វារព្រំដែន** សំដៅដល់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារតំបន់ព្រំដែន។
- **ច្រកទ្វារព្រំដែនអន្តរជាតិ** មានន័យថា ច្រកទ្វារសម្រាប់ការឆ្លងកាត់ព្រំដែនរបស់ពលរដ្ឋនៃភាគីកិច្ចព្រមព្រៀង និងពលរដ្ឋនៃប្រទេសដទៃទៀត។
- **ច្រកទ្វារតំបន់ព្រំដែន** មានន័យថា ច្រកទ្វារសម្រាប់ចេញ-ចូលតំបន់ព្រំដែនរបស់ពលរដ្ឋនៃភាគីកិច្ចព្រមព្រៀងដែលស្នាក់នៅអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែន។

## ជំពូកទី២

## គោលការណ៍នៃការគ្រប់គ្រង និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ

**មាត្រា ៥.-**

ត្រូវបានបង្កើតប័ណ្ណព្រំដែនកម្ពុជា-ថៃសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ ដូចមានគំរូភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៦.-**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចក្នុងការគ្រប់គ្រងការផលិត ការចាត់ចែង និងការត្រួតពិនិត្យការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃជូនដល់ប្រជាពលរដ្ឋខ្មែរ ដោយធានាឲ្យបាននូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសប្រតិភូកម្មអំណាចជូនដល់អភិបាលខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ ក្នុងការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃសម្រាប់ជូនប្រជាពលរដ្ឋខ្មែរ ដើម្បីប្រើប្រាស់។

**មាត្រា ៧.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃ ត្រូវបានផ្តល់ជូនចំពោះតែប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅតាមបណ្តាខេត្តនានានៃព្រះរាជាណាចក្រកម្ពុជាដែលមានព្រំដែនជាប់ជាមួយព្រះរាជាណាចក្រថៃ។

ត្រូវបានហាមឃាត់ដាច់ខាតចំពោះការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលពុំមានលំនៅឋានអចិន្ត្រៃយ៍នៅតាមបណ្តាខេត្តនានានៃព្រះរាជាណាចក្រកម្ពុជាដែលមានព្រំដែនជាប់ជាមួយព្រះរាជាណាចក្រថៃ។

**មាត្រា ៨.-**

អ្នកកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃត្រូវគោរពឲ្យបានត្រឹមត្រូវតាមច្បាប់ និងកិច្ចព្រមព្រៀងនានាជាធរមាន។

## ជំពូកទី៣

## យន្តការ បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ

**មាត្រា ៩.-**

អភិបាលខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជាជាមួយព្រះរាជាណាចក្រថៃ ត្រូវទទួលខុសត្រូវក្នុងការដឹកនាំ ចាត់ចែង និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ត្រូវរៀបចំយន្តការនៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនប្រជាពលរដ្ឋខ្មែរនៅក្នុងទីតាំងសាលាខេត្ត ឬទីតាំងផ្សេងៗទៀតដែលកំណត់ដោយរដ្ឋបាលខេត្ត ស្របទៅតាមគោលការណ៍ដូចបានកំណត់នៅក្នុងជំពូកទី២នៃអនុក្រឹត្យនេះ។

**មាត្រា ១០.-**

បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃជូនដល់ប្រជាពលរដ្ឋខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១១.-**

កម្រៃ និងរយៈពេលនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃជូនដល់ប្រជាពលរដ្ឋខ្មែរ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤

## សុពលភាពប័ណ្ណព្រំដែនកម្ពុជា-ថៃ និងរយៈពេលស្នាក់នៅ

**មាត្រា ១២.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃមានសុពលភាពរយៈពេល ០២ឆ្នាំ និងអាចបន្តសុពលភាពបានយ៉ាងយូរ ០២ឆ្នាំ។

**មាត្រា ១៣.-**

ប្រជាពលរដ្ឋខ្មែរដែលកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃមានសុពលភាព ត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរចេញចូលឆ្លងកាត់ព្រំដែនតាមច្រកទ្វារព្រំដែនផ្លូវការរវាងខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា និងខេត្តជាប់ព្រំដែនដែលនៅទល់មុខគ្នានៃព្រះរាជាណាចក្រថៃ លើកលែងតែមានការកំណត់ដោយឡែក ដោយមានការព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ។

ប្រជាពលរដ្ឋខ្មែរដែលកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃអាចធ្វើដំណើរ ឬស្នាក់នៅក្នុងទឹកដីរបស់ភាគីថៃក្នុងថេរវេលាដែលបានកំណត់ក្នុងអនុក្រឹត្យនេះ និងត្រូវបានអនុញ្ញាតឲ្យចេញតាមច្រកទ្វារព្រំដែនដែលបានចូល។

**មាត្រា ១៤.-**

ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ថៃក្នុងគោលបំណងដូចជា ទៅសួរសុខទុក្ខញាតិសន្តាន ទេសចរណ៍ ភារកិច្ចផ្លូវការ ជំនួញ កីឡា ធ្វើការងារប្រចាំថ្ងៃឬការងារតាមរដូវកាល ចូលរួមសិក្ខាសាលា កិច្ចប្រជុំ សន្និសីទ និងគោលបំណងផ្សេងទៀតតាមការព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ។

**មាត្រា ១៥.-**

ប្រជាពលរដ្ឋខ្មែរដែលកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃអាចស្នាក់នៅខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រថៃក្នុងរយៈពេលមិនលើសពី ០៧ថ្ងៃក្នុងពេលចូលម្តង។ ចំពោះការស្នាក់នៅរយៈពេលយូរ ប៉ុន្តែមិនលើសពី ១៥ថ្ងៃ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃភាគីថៃ។ រយៈពេលស្នាក់នៅនេះអាចមានការកែប្រែ ស្របទៅតាមការព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ។

ប្រជាពលរដ្ឋខ្មែរដែលកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃដែលបានបំពេញលក្ខខណ្ឌ និងនីតិវិធីថ្មីក្នុងពាក់ព័ន្ធនឹងការងារប្រចាំថ្ងៃ និងការងារតាមរដូវកាល ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅចំនួន ៣០ថ្ងៃនៅខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រថៃ។

## ជំពូកទី៥

## ទោសប្បញ្ញត្តិ

**មាត្រា ១៦.-**

អ្នកក្លែងក្លាយ អ្នកលួចផលិតក្លែងបន្លំ អ្នកកោសលុប អ្នករាយការណ៍ ឬផ្តល់ព័ត៌មានមិនពិត និងអ្នកប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ថៃក្លែងក្លាយ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ឬ/និងផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**មាត្រា ១៧.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃដែលចេញឲ្យប្រើប្រាស់មុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបានអនុញ្ញាតឲ្យបន្តប្រើប្រាស់រហូតដល់អស់សុពលភាព។

អាជ្ញាធរមានសមត្ថកិច្ចពុំត្រូវបានអនុញ្ញាតឲ្យបន្តសុពលភាពលើប័ណ្ណព្រំដែនកម្ពុជា-ថៃ ដែលចេញឲ្យប្រើប្រាស់មុនពេលចេញអនុក្រឹត្យនេះឡើយ។

# ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ ស្តីពីការប្រើប្រាស់ប័ណ្ណព្រំដែននៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៤ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ